**ជូនចំពោះ**
លោកជំទាវ យីង ឡាក់ ស៊ីណាវ៉ាត់ត្រា នាយករដ្ឋមន្ត្រីប្រទេសថៃ
ឯកឧត្តម ថុងស៊ីងថាមម៉ាវ៉ង់ នាយករដ្ឋមន្ត្រីប្រទេសឡាវ

**ចំលងជូន**
ឯកឧត្តម ឈូមម៉ាលី សាយ៉ាស៊ុន ប្រធានាធិបតីប្រទេសឡាវ

យើងខ្ញុំដែលជាហត្ថលេខីសូមសំដែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះគម្រោងសាងសង់ទំនប់វារីអគ្គីសនីសាយ៉ាបូរីនៅភាគខាងជើងប្រទេសឡាវ និងគ្រោះកម្មដែលអាចកើតមានឡើងនៅអាងទន្លេមេគង្គក្រោម។

ទំនប់នេះគឺគំរាមកំហែងជីវិត និងសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋរាប់លាននាក់។ ទន្លេមេគង្គជាជំរកដ៏ធំសម្បើមនៃជម្រុកត្រីទឹកសាប និងជាតំបន់ទន្លេមេគង្គដែលពោរពេញដោយធនធានធម្មជាតិសំខាន់ៗ។

អ្នកវិទ្យាសាស្ត្រជាច្រើនបានយល់ស្របថាទំនប់វារីអគ្គីសនីសាយ៉ាបូរីអាចផ្តល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់បរិស្ថាន សង្គម និងសេដ្ឋកិច្ចនៅក្នុងតំបន់ ដោយផលប៉ះពាល់ទាំងអស់នេះគឺមិនអាចបន្ធូរបន្ថយបានទេ។

វានូវមានចន្លោះខ្វះខាតច្រើនក្នុងការយល់ដឹងលំអិតពីផលប៉ះពាល់ដែលអាចកើតឡើងពីទំនប់នេះ ហើយតាមលទ្ធផលស្រាវជ្រាវស្តីពី*ការវាយតំលៃផលប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ*របស់គណៈកម្មការទន្លេមេគង្គបានផ្តល់អនុសាសន៍ឱ្យពន្យាពេល១០ឆ្នាំដើម្បីសិក្សាស្រាវជ្រាវបន្ថែមមុនពេលធ្វើការសំរេចចិត្តលើគម្រោងទាំងឡាយនៅតាមដងទន្លេមេនៃទន្លេមេគង្គ ។

យើងខ្ញុំបានដឹងថាការសំរេចចិត្តឱ្យមានការសាងសង់ទំនប់សាយ៉ាបូរីនឹងចាប់ផ្តើមនៅខែវិច្ឆិកាខាងមុខនេះ។ ក្នុងពេលជាមួយគ្នានេះដែរ ការកើនឡើងនូវទឹកជំនន់និងកង្វះស្បៀងកំពុងតែកើតឡើងនៅក្នុងតំបន់ទន្លេមេគង្គ ដូចនេះយើងខ្ញុំសូមស្នើសុំរាជរដ្ឋាភិបាលប្រទេសឡាវ និង ប្រទេសថៃដូចខាងក្រោម ៖

១. សូមបញ្ឈប់គម្រោងសាងសង់ទំនប់សាយ៉ាបូរី និងពន្យាពេលការសំរេចចិត្តយ៉ាងតិច១០ឆ្នាំ រហូតដល់មានការស្រាវជ្រាវបន្ថែមទៀត។

២. សូមរាជរដ្ឋាភិបាលថៃបញ្ឈប់ផែនការទិញថាមពលអគ្គីសនីពីទំនប់សាយ៉ាបូរី និងទំនប់វារីអគ្គីសនីផ្សេងទៀតនៅតាមដងទន្លេមេនៃទន្លេមេគង្គ។

សូមឯកឧត្តម លោកជំទាវទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។